## នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2014, 08:35
CMS/CFO: Phok Chanthan

### ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ការឆ្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីលោក នួន ជា ទៅនឹងសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

**នៅចំពោះមុខ៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន

ចៅក្រម A. KLONOWIECKA-MILART

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម C.N. JAYASINGHE

ចៅក្រម ម៉ុង មុនីចរិយា

ចៅក្រម យ៉ា ណារិន

ឡា ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Olivier BAHOUGNE
Patrick BAUDOIN
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Julien RIVET
Nushin SARKARATI
Beini YE
Mahesh RAI

ចៅក្រម Florence Ndepele Mwachande MUMBA

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

នួន ជា

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

## I. សេចក្ដីផ្ដើម

1. នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្ដីលោក នួន ជា បានឆ្លើយតបទៅនឹងសំណើសុំរបស់សហមេធាវីនាមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធទៅនឹងបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ (ហៅថា "សហមេធាវីនាមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី" និង "សំណើសុំ")[1]។ អនុលោមតាមមាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សហមេធាវីនាមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងចម្លើយតបរបស់លោក នួន ជា ដូចខាងក្រោមនេះ[2]។ សហមេធាវីនាមុខបានស្នើសុំ និងទទួលបានការអនុញ្ញាតឲ្យដាក់ចម្លើយតបតែមួយភាសា[3]។

2. *ក្នុងចំណោមទឡ្ហីករណ៍នានា* មេធាវីការពារក្ដីបានអះអាងថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនមាន "សមភាព" ស្មើនឹងភាគីដទៃទៀតទេ ហើយការចូលរួមក្នុងបណ្ដឹងសាទុក្ខរបស់ពួកគេនឹងបម្លែងដោយមិនសមស្របនូវឋានៈរបស់សហមេធាវីនាំមុខឲ្យទៅជាសហព្រះរាជអាជ្ញាទីពីរ ហើយវាជាការបំពានសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[4]។ ហេតុដូច្នេះពួកគេបានស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលសំណើនេះទាំងស្រុង ហើយប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចតាមសំណើសុំនេះ ត្រូវឲ្យដាក់សំណើសុំនេះទាំងពីរភាសា ទាំងភាសាអង់គ្លេស និងភាសាខ្មែរ រួមទាំងសុំឲ្យសម្រេចផ្ដល់ពេលវេលាបន្ថែមទៀតសម្រាប់រៀបចំទឡ្ហីករណ៍ផ្ទាល់មាត់ផងដែរ។

3. ដូចបានរៀបរាប់ខាងក្រោមនេះ ចម្លើយតបរបស់លោក នួន ជា បានផ្អែកលើការបកស្រាយខុសលើតួនាទីចូលរួមរបស់សហមេធាវីនាំមុខ និងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងដំណាក់កាលបណ្ដឹងសាទុក្ខ។

## II. ការឆ្លើយតប

---

[1] ចម្លើយតបរបស់មេធាវីលោក នួន ជា ទៅនឹងសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១, F10/1 ថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ("ចម្លើយតបរបស់ នួន ជា")។

[2] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក កំណែលើកទី ៨ ថ្ងៃទី ១ ឆ្នាំ ២០០៧។

[3] *សូមមើល* អ៊ីម៉ែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះជូនភាគី ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤។

4. កថាខណ្ឌ ២ នៃចម្លើយតបរបស់ នួន ជា បានអះអាងថា ការឆ្លើយតបបានផ្អែកលើ "ការសន្និដ្ឋានតាមន័យបកស្រាយ" ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសមភាពស្មើនឹងភាគីដទៃទៀតក្នុងសំណុំរឿង ០០២។ សហមេធាវីនាំមុខសូមបញ្ជាក់ថា និយមន័យពាក្យថា "ភាគី" ក្នុងវិធានផ្ទៃក្នុង បានចែងដោយគ្មានចំណុចសង្ស័យថា "ដើមបណឹងប្បវេណី" ត្រូវបានបញ្ចូលក្នុងពាក្យនេះ[5]។ សូមបញ្ជាក់ថា "ស្មើភាពគ្នា" មិនមែនមានន័យថា តួនាទីរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី គឺដូចគ្នាសុទ្ធសាធ និង/ឬអាចដាក់ជំនួសគ្នាបានទេ ប៉ុន្តែគ្រាន់តែមានន័យថា តាមរយៈជា "ភាគី" នៃកិច្ចដំណើការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានសមភាពស្មើនឹងភាគីដទៃដែរ[6]។ លើសពីនេះទៀត មេធាវីការពារក្តី នួន ជា បានយោងទៅសំណើពីមុនដែលគ្មានភាពទាក់ទងដែលសហមេធាវីនាំមុខបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីការធ្វើសេចក្តីថ្លែងក្នុងនាមបណ្តុំក្រុមដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខយល់ថា មូលហេតុដែលត្រូវបានលើកឡើងក្នុងកាលៈទេសៈពិសេសក្នុងពេលជំនុំជម្រះមិនមានភាពពាក់ព័ន្ធនឹងសំណើសុំនេះ[7]។

5. កថាខណ្ឌ ៣ មេធាវីការពារក្តីរបស់ នួន ជា អះអាងថា ការសន្និដ្ឋានដែលបានលើកឡើង ផ្ទុយទៅនឹងច្បាប់កម្ពុជា យុត្តិសាស្ត្ររបស់ អ.វ.ត.ក វិធានផ្ទៃក្នុង និងការអនុវត្តន៍របស់សាលាក្តីអន្តរជាតិ ដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ "ICC"។ ពាក់ព័ន្ធនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក សហមេធាវីនាំមុខសូមឲ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាយោងទៅទឡ្ហីករណ៍ទាំងឡាយដែលត្រូវបានលើកឡើងក្នុងកថាខណ្ឌ ៨-១២ នៃសំណើសុំរបស់ខ្លួន[8]។ សំណុំសុំនេះមិនផ្ទុយនឹងច្បាប់កម្ពុជាទេ

---

[4] *សូមមើល* វិធានផ្ទៃក្នុង ៨១ "ភាគី"។

[5] ខុសពីការចូលរួមរបស់ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ កាលណាជនរងគ្រោះមិនមែនជាភាគី ប៉ុន្តែជា "អ្នកចូលរួម" ក្នុងកិច្ចដំណើរការនីតិវិធី ប្រសិនបើពួកគេមិនធ្វើជាសាក្សី។

[6] សហមេធាវីនាំមុខសូមចង្អុលបង្ហាញថា សំណើធ្វើសេចក្តីថ្លែងការណ៍បើកក្នុងនាមបណ្តុំក្រុមដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធដោយផ្អែកតែលើមូលដ្ឋានថា គ្មានបទប្បញ្ញត្តិចែងជាក់លាក់ក្នុងវិធានផ្ទៃក្នុងជាធរមាន។ អង្គជំនុំជម្រះមិនបានចេញសេចក្តីសម្រេចណាមួយអំពីតួនាទីរបស់សហមេធាវីនាំមុខពាក់ព័ន្ធនឹងបញ្ហានេះក្នុងពេលជំនុំជម្រះ ឬបណ្តឹងសាទុក្ខឡើយ។ សូមអាន សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខ ដើម្បីធ្វើសេចក្តីថ្លែងការណ៍បើក ឯកសារ E316/1 ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៤។

[7] *ដកស្រង់ចេញពី* វិធានផ្ទៃក្នុង ២១(១)(ក), ១២ស្ទួនពីរ(១), ១២ ស្ទួនពី (៥)(ខ), ២៣ (១)(ក) អានរួមជាមួយមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ នស/រកម/១០០៤/០០៦។

ហើយតាមពិតទៅ ច្បាប់បានចែងយោងទៅតួនាទីទូលាយរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលបណ្តឹងសាទុក្ខ[9]។ ចំណុចចុងក្រោយ ទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិមិនបានចែងពីការចូលរួមរបស់ជនរងគ្រោះក្នុងរចនាសម្ព័ន្ធរបស់ខ្លួនក្តី ក៏មានភាពខុសគ្នាទាំងស្រុងរវាងការតំណាងជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងនៅ អ.វ.ត.ក ផងដែរ។ មេធាវីការពារក្តីមិនអាចប្រៀបប្រដូចការអនុវត្តន៍របស់តុលាការទាំងពីរនេះឡើយ ហើយក្នុងបរិបទពិសេសនេះ មេធាវីការពារក្តីមិនអាចចាត់ទុកការអនុវត្តន៍នេះជាករណីយុត្តិសាស្ត្រសម្រាប់ អ.វ.ត.ក បានឡើយ។

6. កថាខណ្ឌ ៣ និង ៤ មេធាវីការពារក្តីរបស់ នួន ជា ក៏បានអះអាងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានដោះស្រាយទាំងស្រុងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានសិទ្ធិទូទៅក្នុងការចូលរួមដោយស្មើភាពគ្នាជាមួយនឹងសហព្រះរាជអាជ្ញាទេ។ សហមេធាវីនាំសូមបញ្ជាក់ថា មេធាវីការពារក្តី នួន ជា បានបំភ្លេចចោលបរិបទដែលនាំឱ្យមានសេចក្តីសម្រេចនេះ ដែលក្នុងករណី អង្គជំនុំជម្រះសាលាដំបូងបានយកទុកដាក់លើតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់ទោសក្នុងអំឡុងពេលដំណើរការនីតិវិធី *ជំនុំជម្រះ*។ ទោះបីជាយ៉ាងណាក្តី សហមេធាវីនាំមុខយល់ស្របលើចំណុចសំខាន់នៃយោបល់ដែលបានបញ្ជាក់ក្នុងសេចក្តីសម្រេចនេះ ហើយសូមបញ្ជាក់ថា គ្មានអ្វីផ្ទុយនឹងសំណើសុំនេះទេ ហើយសេចក្តីសម្រេចនេះបានទទួលស្គាល់តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជួយគាំទ្រដល់ការចោទប្រកាន់ ដោយទទួលស្គាល់ថា ភាគីនីមួយៗ “មានតួនាទីខុសគ្នា ក្នុងការរក្សាផលប្រយោជន៍ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការជំនុំជម្រះក្តី”[10]។ លើសពីនេះទៅទៀត សេចក្តីសម្រេចត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០០៩ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកែប្រែយ៉ាងច្រើន ដោយសារការធ្វើវិសោធនកម្មបន្ទាប់ពីខែកញ្ញា ឆ្នាំ ២០០៩ ចំណុចដែលគួរឱ្យកត់សំគាល់ខ្លាំងគឺសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹង

[8] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៧៥ (ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងសាទុក្ខលើបញ្ហារដ្ឋប្បវេណីនៃរឿងក្តី) មាត្រា ៣៩១ (ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឱ្យប្តឹងសាទុក្ខចំពោះមុខសាលាឧទ្ធរណ៍) មាត្រា ៣៨៨ (ការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការបណ្តឹងសាទុក្ខ) មាត្រា ៣៩៤ (សវនាការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងសាទុក្ខ)។

[9] សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានការសម្រេចពីស្ថានភាពរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋានពីការកំណត់ទោស និងសេចក្តីសម្រេចពាក់ព័ន្ធនឹងតាងសំណួរទៅជនជាប់ចោទ អ្នកជំនាញ សាក្សីដែលធ្វើសក្ខីកម្មពីអត្តចរិត សំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក./អជសដ ឯកសារ E72/3 ចុះថ្ងៃទី ៩ ខែតុលា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥។

សាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខ[11]។ ដូច្នេះ ការប្រើសេចក្តីសម្រេចនេះដើម្បីដាក់កំហិតលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្តឹងសាទុក្ខ មិនសមស្របឡើយ។

7. កថាខណ្ឌ ៥ មេធាវីការពារក្តីរបស់ នួន ជា បានគិតថា ប្រសិនបើតុលាការអនុញ្ញាតឲ្យសហមេធាវីនាំមុខឆ្លើយតបទៅនឹងរាល់មូលហេតុទាំងអស់ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងនាំឲ្យ "មេធាវីការពារក្តីត្រូវប្រឈមមុខនឹងភាគីពីរ ដែលភាគីនីមួយៗប្រើវិធីសាស្ត្ររឿងក្តីខុសពីគ្នាដែលផ្តោតទៅលើពិរុទ្ធភាព នួន ជា" ដែលជាហេតុនាំមានការបម្លែងសហមេធាវីនាំមុខឲ្យទៅជាសហព្រះរាជអាជ្ញាទីពីរ ដែលនាំឲ្យមានការបំពានលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សហមេធាវីនាំមុខសូមបញ្ជាក់ថាដើមបណ្តឹងរដ្ឋប្បវេណីមិនប្រើសិទ្ធិដើម្បីប្តឹងសាទុក្ខឡើយ បើខ្លួនគ្មានសិទ្ធិនេះទេ ប៉ុន្តែខ្លួនត្រូវប្រើសិទ្ធិឆ្លើយតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍ តែត្រឹមកម្រិតដែលសារណានេះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ខ្លួនតែប៉ុណ្ណោះ។ ការធ្វើបែបនេះមិនបង្កើតបានជាការចោទប្រកាន់បន្ថែមតាមរបៀបដូចគ្នានឹងការចូលរួមរបស់ពួកគេក្នុងពេលជំនុំជម្រះ ដែលពាក់ព័ន្ធទៅនឹងការបញ្ជូនបញ្ជីសាក្សី ការផ្តល់សក្ខីកម្មផ្ទាល់មាត់លើអង្គហេតុចោទប្រកាន់ ការសួរដេញដោលសាក្សី ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលឡើយ ហើយក៏មិនត្រូវចាត់ទុកថាជាការចោទប្រកាន់បន្ថែមដែរ។ បណ្តុំក្រុមដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយសហមេធាវីនាំមុខ ដើម្បីចូលរួមក្នុងបណ្តឹងព្រហ្មទណ្ឌ "បណ្តឹងសាធារណៈ" ដែលដឹកនាំដោយសហព្រះរាជអាជ្ញាប្រឆាំងនឹងជនជាប់ចោទ ហើយមិនធ្វើបណ្តឹងព្រហ្មទណ្ឌស្របគ្នាជាមួយសហព្រះរាជអាជ្ញាប្រឆាំងនឹងជនជាប់ចោទទេ។ សហមេធាវីនាំមុខមានការទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងមូលដ្ឋានពាក់ព័ន្ធក្នុងបណ្តឹងសាទុក្ខ តែត្រឹមកម្រិតដែលអង្គជំនុំជម្រះតុលាការកំពូលអាចសម្រេចលើការកំណត់បទចោទ និងផលវិបាក ដែលជាបញ្ហាអង្គច្បាប់ និងបញ្ហាអង្គហេតុ នៃភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។

8. កថាខណ្ឌ ៥ មេធាវីការពារក្តីរបស់ នួន ជា បានអះអាងថា សហព្រះរាជអាជ្ញាមិនបានបង្ហាញចេតនាថា ពួកគេនឹងផ្តល់ឱកាសឲ្យសហមេធាវីនាំមុខផ្តល់ចម្លើយតបណាមួយទៅនឹងរាល់មូលហេតុ

---

[10] *សូមមើល* វិធានផ្ទៃក្នុង ១០៥(១)(គ) នៃវិធានផ្ទៃក្នុង (វិសោធនកម្ម ៦) ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០១០ រួមជាមួយវិធាន ១០៥(១)(គ) នៃវិធានផ្ទៃក្នុង (វិសោធនកម្ម ៤) ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៩។

ទាំងអស់ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ សហមេធាវីនាំបញ្ជាក់ថា មេធាវីការពារក្តី នួន ជា បានបកស្រាយខុសអំពីតួនាទីរបស់សហព្រះរាជអាជ្ញា ដែលមិនត្រូវមានកាតព្វកិច្ចប្តឹងសាទុក្ខ ឬឆ្លើយតបទៅនឹងមូលហេតុពាក់ព័ន្ធទៅនឹងមុខងារ និងភាពពាក់ព័ន្ធនៃភស្តុតាង ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នោះឡើយ។ ក្នុងករណីដែលសហព្រះរាជអាជ្ញាមិនបានលើកពីមូលដ្ឋានបណ្តឹងសាទុក្ខចំនួនប្រហែល ៨០ នៅក្នុងសារណាឆ្លើយតបរបស់ពួកគេទេ សហមេធាវីនាំមុខនឹងគ្មានឱកាសក្នុងការតំណាងផលប្រយោជន៍កូនក្តីរបស់ខ្លួនឡើយ។ ការធ្វើបែបនេះនឹងប៉ះពាល់យ៉ាងខ្លាំងទៅលើស្មារតីនៃការតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក និងជាការបដិសេធគោលបំណងរបស់ អ.វ.ត.ក។ មេធាវីការពារក្តី នួន ជាមិនបានគិតថា មូលដ្ឋាន ៣៤ (រួមជាមួយមូលដ្ឋាន ១១ ២៨ និង ២៩) ក្នុងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខរបស់ខ្លួនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងចរិតលក្ខណៈ និងតម្លៃនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មស្តីពីការប៉ះពាល់ដល់ជនរងគ្រោះ ដែលសហមេធាវីនាំមុខជាអ្នកមានការទទួលខុសត្រូវចម្បងក្នុងការឆ្លើយតប[12]។

9. កថាខណ្ឌ ៦ មេធាវីការពារក្តីរបស់ នួន ជា បានតវ៉ាថា សំណើសុំរបស់សហមេធាវីនាំមុខពាក់ព័ន្ធទៅនឹងការបន្ថែមពេលវេលា និងការដាក់សារណាឆ្លើយតបតែមួយភាសា មានភាពផ្ទុយគ្នា។ មេធាវីការពារក្តីរបស់ នួន ជា បានយកការទទួលខុសត្រូវក្នុងការពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ទៅបញ្ចូលជាមួយការសម្របសម្រួលការតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលជំនុំជម្រះ។ ច្បាប់បានអនុញ្ញាតឲ្យសហមេធាវីនាំមុខតំណាងឲ្យផលប្រយោជន៍របស់បណ្តុំក្រុមដើមបណ្តឹងរដ្ឋប្បវេណី[13]។ បញ្ញត្តិនេះតម្រូវឲ្យមានការពិគ្រោះយោបល់ជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុនពេលសហមេធាវីនាំមុខធ្វើសេចក្តីសន្និដ្ឋានជូនតុលាការ។ ដូចដែលបានបញ្ជាក់ក្នុងសំណើសុំសហមេធាវីនាំមុខអាចទទួលបានមតិយោបល់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានតែក្នុងករណីដែលខ្លួនទទួលបានសារណាបណ្តឹងសាទុក្ខជាភាសាខ្មែរ។ ទោះបីជាយ៉ាងណាក្តី បន្ទាប់ពីបានបង្កើតយោបល់រួមផ្អែកតាមទស្សនៈទាំងនោះ សហមេធាវីនាំមុខគឺជាអ្នកមានការទទួលខុសត្រូវចុងក្រោយចំពោះមុខតុលាការក្នុងការងារតំណាង យុទ្ធសាស្ត្រ និងការតំណាងផលប្រយោជន៍របស់

---

[11] *សូមមើលផងដែរ* មូលដ្ឋាន ១១, ២៨ និង ២៩ ពាក់ព័ន្ធនឹងការបំពានសិទ្ធិជនជាប់ចោទក្នុងការតទល់នឹងភស្តុតាងប្រឆាំងនឹងខ្លួន ក្នុងចំណោមនោះ រួមទាំង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សក្ខីកម្មពីផលប៉ះពាល់លើជនរងគ្រោះ និងភស្តុតាងផ្សេងទៀតដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់។

[12] វិធានផ្ទៃក្នុង ១២ ស្ទួនពីរ (៥)(ក)

បណ្តុំក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការ[14]។ ក្នុងគោលបំណងនេះ ការដាក់សំណើតែមួយភាសា ដែលនឹងមានការបកប្រែទៅជាភាសាខ្មែរតាមក្រោយក្នុងពេលឆាប់ៗ មិនប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬរបស់មេធាវីការពារក្តីរបស់ នួន ជា ទេ ហើយវាជាការបង្ហាញពីតុល្យភាពសមស្របរវាងភាពចាំបាច់ខាងពេលវេលា និងភាពយុត្តិធម៌។

## III. សំណើ

**អាស្រ័យដូចមូលហេតុខាងលើ** ដើមបណ្តឹងរដ្ឋប្បវេណីសូមគោរពស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

១. **អនុញ្ញាតឲ្យ**សហមេធាវីនាំមុខឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខដែលសហជនជាប់ចោទបានដាក់ជូនតុលាការ និង

២. **សម្រេចតាម**សំណើសុំរបស់សហមេធាវីនាំមុខក្នុងការដាក់ជូនសារណាឆ្លើយតបជាភាសាអង់គ្លេស ដោយបញ្ជូនសំណើបកប្រែទៅជាភាសាខ្មែរតាមក្រោយក្នុងពេលឆាប់ៗខាងមុខ។

សូមអង្គជំនុំជម្រះតុលាការកំពូលមេត្តាទទួលនូវសេចក្តីគោរពអំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | នាមនិងគោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៩ ធ្នូ ឆ្នាំ២០១៤ | សហមេធាវីនាំមុខ<br>**ពេជ្រ អង្គ** | ភ្នំពេញ | |
| | សហមេធាវីនាំមុខ<br>Marie GUIRAUD | ភ្នំពេញ | |

[13] វិធានផ្ទៃក្នុង ១២ ស្ទួនពីរ (៥)(ខ)